**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សេចក្តីប្រកាសព័ត៌មាន**
**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧**

## គណៈកម្មាធិការទទួលបន្ទុកពិនិត្យវិធានផ្ទៃក្នុងនៃ អ.វ.ត.ក បញ្ចប់កិច្ចប្រជុំ

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ គណៈកម្មាធិការទទួលបន្ទុកពិនិត្យបានបញ្ចប់កិច្ចប្រជុំរយៈពេលពីរសប្តាហ៍ នៅរាជធានីភ្នំពេញ ទៅលើសេចក្តីព្រាងវិធានផ្ទៃក្នុង។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិចារណាឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ទៅលើបញ្ហានានាដែលបានលេចឡើងនូវការខ្វែងយោបល់គ្នានៅក្នុងកិច្ចប្រជុំពេញអង្គ ដែលបានប្រារព្ធធ្វើកាលពីខែវិច្ឆិកា ឆ្នាំ២០០៦ ដើម្បីវិភាគ និងពិភាក្សាអំពីមូលដ្ឋានគតិយុត្តិចំពោះជំហរខុសៗគ្នា និងដើម្បីស្វែងរកដំណោះស្រាយ។

នៅពេលបញ្ចប់កិច្ចប្រជុំរបស់ខ្លួន គណៈកម្មាធិការទទួលបន្ទុកពិនិត្យបានធ្វើសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖

> *សមាជិកគណៈកម្មាធិការទទួលបន្ទុកពិនិត្យដែលស្នាក់នៅរាជធានីភ្នំពេញ បានបំពេញការងារជាប្រចាំចាប់តាំងពីកិច្ចប្រជុំពេញអង្គនៅខែវិច្ឆិកា ដើម្បីរៀបចំមូលដ្ឋានសម្រាប់កិច្ចប្រជុំពេញលេញរបស់គណៈកម្មាធិការ។ ជាលទ្ធផលនៃកិច្ចពិភាក្សាស៊ីជម្រៅ គេបានរកឃើញដំណោះស្រាយចំពោះការខ្វែងយោបល់គ្នាជាច្រើនចំណុច ហើយបញ្ហាដែលនៅសេសសល់នឹងត្រូវនាំយកទៅពិភាក្សានៅឯកិច្ចប្រជុំរបស់គណៈកម្មាធិការ នៅសប្តាហ៍នេះ។*

> *មានវឌ្ឍនភាពយ៉ាងធំធេងក្នុងអំឡុងពេលកិច្ចប្រជុំពីរសប្តាហ៍របស់គណៈកម្មាធិការទទួលបន្ទុកពិនិត្យ ដោយបានបង្រួមបញ្ហាលេចធ្លោមួយចំនួន។ ទោះជាយ៉ាងនេះក្តី នៅមានបញ្ហា*

*ចម្បងៗចំនួនបីដែលត្រូវដោះស្រាយឲ្យបានពេញលេញ ដូចជាថាតើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិគួរច្រូបាច់បញ្ចូលគ្នាបែបណាទៅក្នុងវិធានផ្ទៃក្នុង ដើម្បីធានាឲ្យមានដំណើរការចុះបញ្ជីដែលមានតម្លាភាព និងយុត្តិធម៌ និងសិទ្ធិពេញលេញក្នុងការចូលរួមរបស់មេធាវីការពារក្តីបរទេសនៅ អ.វ.ត.ក។*

*យើងបានឯកភាពគ្នាថា សមាជិកដែលស្នាក់នៅរាជធានីភ្នំពេញនឹងបន្តបំពេញការងារ ហើយកិច្ចប្រជុំមួយទៀតរបស់គណៈកម្មាធិការទទួលបន្ទុកពិនិត្យនឹងរៀបចំនៅខែមីនា។ នៅពេលដែលសេចក្តីព្រាងវិធានផ្ទៃក្នុងត្រូវបានបញ្ចប់ សេចក្តីព្រាងនេះនឹងដាក់ជូនចៅក្រមនៃកិច្ចប្រជុំពេញអង្គ។*

*យើងដឹងយ៉ាងច្បាស់ពីភាពចាំបាច់ដើម្បីធានាឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងជាចំហ សម្រាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជា ហើយយើងគ្រប់រូបប្តេជ្ញាសម្រេចឲ្យបានទៅតាមគោលដៅនេះ។*

សាវតា

វិធានផ្ទៃក្នុងត្រូវរួមបញ្ចូលគ្នារវាងនីតិវិធីជាធរមាននៅកម្ពុជា សម្រាប់កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ហើយត្រូវអនុម័តតាមវិធានបន្ថែមទៀតដែលនីតិវិធីមានស្រាប់មិនបានឆ្លើយតបទៅនឹងបញ្ហាជាក់លាក់ណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការបកស្រាយវិធាន ឬការអនុវត្តន៍ ឬប្រសិនបើមានបញ្ហាណាមួយពាក់ព័ន្ធនឹងភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិ។

គណៈកម្មាធិការទទួលបន្ទុកវិធានមានសមាសភាពចៅក្រមជាតិបីរូប និងចៅក្រមបរទេសពីររូប រួមមាន លោកចៅក្រម យូ ប៊ុនឡេង លោកចៅក្រម ម៉ុង មុន្នីចរិយា លោកចៅក្រម ប្រាក់ គឹមសាន លោកស្រីចៅក្រម Agnieszka Klonowiecka-Milart និង លោកចៅក្រម Marcel Lemonde។ សម្រាប់គោលបំណងនៃដំណើរការពិនិត្យនេះ សមាជិកបួនរូបទៀតត្រូវបានដាក់បន្ថែមគឺ៖ ចៅក្រមជាតិរួមមាន លោកចៅក្រម គង់ ស្រីម និង លោកចៅក្រម ស៊ិន រិទ្ធ និង ចៅក្រមអន្តរជាតិរួមមាន លោកស្រីចៅក្រម Silvia Cartwright និង លោកស្រីចៅក្រម Claudia Fenz ដែលសរុបមានចៅក្រមប្រាំបួនរូប។